# ការសំភាសន៍របស់អ៊ុំស្រី សៅ ចំរើន

កៈ អ្នកដែរសំភាសន៍ ជាងស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ សៅ ចំរើន

## ការសង្ខេបប្រវត្តិរបស់អ៊ុំស្រី សៅ ចំរើន

អ៊ុំស្រី សៅ ចំ រើន មានអាយុ53 ឆ្នាំនៅក្នុងឆ្នាំ 2018។អ៊ុំស្រី សៅ ចំរើន មានភេទស្រី។អ៊ុំស្រី សៅ ចំរើន មានទីលំនៅបច្ចុប្បន្ននៅភូមិស្វាយរលំ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល។

កៈ ចឹងជាដំបូងខ្ញុំសូមអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍ នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយ នឹងប្រវត្តិរបស់ដូចតា ចឹងនៅពេលដែរខ្ញុំបាន សំភាសន៍អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមាន ឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសអ៊ុំ ចឹងតើអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ ចាំ!!!

កៈ អ៊ុំតល់ព្រមដើម្បីអោយខ្ញុំសំភាសន៍អ៊ុំទេអ៊ុំ?

ខៈ យល់ព្រមធ្វើអីគេ?

កៈ សំភាសន៍អ៊ុំហាសពីប្រវត្តិរបស់អ៊ុំហាស?

ខៈ សំភាសន៍មានការអីគេ និយាយពីរឿងអីគេខ្លះដែរទៅ?

កៈ សួរពីប្រវត្តិរបស់អ៊ុំថាកាលពីនៅក្មេងអ៊ុំធ្លាប់មានទុកលំបាកអីគេខ្លះដែរចឹងហាស?

ខ៖  អូ!ខ្ញុំនៅពីក្មេងនឹងខ្ញុំដើរស៊ីឈ្នួលគេដែរនឹង ស៊ីឈ្នួលដើរកាប់អំពៅ ដើរប៉ះប៉ាវអោយគេខ្ញុំនៅវែកដីពីរ នាក់ប្តីប្រពន្ធរបស់ខ្ញុំហោស

ក៖  ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍ពូខ្ញុំមានឈ្មោះថា ជាង ស៊ីអាវ ហើយថ្ងៃខែដែរការសំភាសន៍មួយនេះត្រូវបាន ធ្វើឡើងនៅថ្ងៃទី22 ខែ2 ឆ្នាំ2018 ហើយសំភាសន៍នៅភូមិស្វាយរលំ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ចឹងសំរាប់អ៊ុំមានឈ្មោះពេញតើងឈ្មោះអីគេដែរអ៊ុំ?

ខ៖  ឈ្មោះសៅ ចំរើន

ក៖  ចុះមានឈ្មោះហៅក្រៅទេអ៊ុំ?

ខ៖  ឈ្មោះខ្ញុំនឹង

ក៖  ឈ្មោះហៅក្រៅឈ្មោះនឹងដែរហោស?

ខ៖  ឈ្មោះ ចំរើន នឹងតែម្តងនឹង

ក៖  ចុះកាលពីក្មេងមាននរណាហៅឈ្មោះអ៊ុំអីផ្សេងទេ?

ខ៖  ឈ្មោះកាលពីក្មេងឈ្មោះតែមួយនឹងគ្មានកែទេឈ្មោះនឹងរហូតនឹង

ក៖  ចុះអ៊ុំឥឡូវនឹងអាយុប៉ុន្មានដែរអ៊ុំ?

ខ៖  អាយុហាជាងហើយនឹង

ក៖  អាយុហាប៉ុន្មានដែរអ៊ុំ?

ខ៖  អាយុ53ឆ្នាំនឹង

ក៖  អូអាយុ53ឆ្នាំហោស

ខ៖  ចូលឆ្នាំថ្មីនឹងអាយុ54ឆ្នាំហើយនឹង

ក៖  ចុះអ៊ុំមានចងចាំថាអ៊ុំបានកើតនៅថ្ងៃខែឆ្នាំណាដែរទេអ៊ុំ?

ខ៖  ចាំ!អត់ចាំផងនឹង ម៉ែខ្ញុំក៏ភ្លេចដែរគាត់មិនដែរបានប្រាប់ខ្ញុំផងនឹង

ក៖  ចឹងអ៊ុំកើតនៅឆ្នាំ1964

ខ៖ ចុះតាំពីសង្គមហោស

ក៖ បាទអ៊ុំ ចុះអ៊ុំកើតនៅណាដែរអ៊ុំ?

ខ៖ កាលពីកើតកំណើតរបស់ខ្ញុំនឹងនៅចុងតំម៉ៅហោស

ក៖ នៅភូមិអី ឃុំអី នៅស្រុកអី ខេត្តអីដែរអ៊ុំ?

ខ៖ នៅភូមិព្រែកសំរោង នៅចុងតាម៉ៅហោស

ក៖ ចុះឃុំអីគេដែរអ៊ុំ?

ខ៖ ឃុំស្អីគេទេនៅចុងតាម៉ៅហោសខ្ញុំមិនបានសួរម៉ែខ្ញុំដែរនឹងហាស អានៅជិតវត្តសំរោងយើងនឹង

ក៖ បាទអ៊ុំបាទ?

ខ៖ ចាំ!នឹងនៅពីសង្គមហោស

ក៖ ចុះនៅស្រុកអីគេដែរអ៊ុំនៅនឹង?

ខ៖ នេះគេហៅស្រុកអីគេទេនៅនឹង

ក៖ ប៉ុន្តែនៅខេត្តកណ្តាលយើងនឹងទេហោសអ៊ុំ?

ខ៖ ដឹងតែនៅចុងតម៉ៅៗយើងនឹងតែម្តងនឹង

ក៖ ប៉ុន្តែដឹងតែនៅខេត្តកណ្តាលយើងនឹងទេហោសអ៊ុំ?

ខ៖ ចាំ!នៅខេត្តកណ្តាលយើងនឹងតែម្តងនឹង

ក៖ អូ៎! ចុះអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ បងប្អូនរបស់ខ្ញុំនឹងមាន3នាក់នឹង

ក៖ ចុះអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំជាកូនទី1នឹង

ក៖ ចុះប្អូនរបស់អ៊ុំមានឈ្មោះអីគេខ្លះដែរអ៊ុំ?

ខ៖  ប្អូនរបស់ខ្ញុំនឹងទី3 ហើយនឹងស្រីទី2

ក៖  ចឹងមានន័យថាអុំមានស្រី2នាក់ នឹងប្រុសមួយម្នាក់?

ខ៖  ចា៎!មានស្រី2នាក់ នឹងប្រុសមួយម្នាក់

ក៖  ចុះប្អូនរបស់អ៊ុំនឹងមានឈ្មោះអីគេខ្លះដែរអ៊ុំ?

ខ៖  ឈ្មោះអា វេង មុំ វេង នឹងឈ្មោះ មុំចាន់ធី

ក៖  ចុះប្អូនពៅរបស់អ៊ុំមានឈ្មោះអីគេដែរអ៊ុំ?

ខ៖  ប្អូនពៅរបស់ខ្ញុំនឹងឈ្មោះ មុំវេង ប្អូនរបស់ខ្ញុំនឹងទៅស៊ីឈ្នួលគេហោស

ក៖  ចុះអ៊ុំមានចងចាំអនុស្សាវរីយ៍អីដែរអ៊ុំធ្លាប់ធ្វើរឺលេងដូចជាលេងឡឹកបាយឡ នឹងលេងបិទពួនអីចឹង ហាសអ៊ុំ?

ខ៖  អត់ចាំដែរនឹង

ក៖  ចុះអ៊ុំធ្លាប់ធ្វើអីគេខ្លះដែរជាមួយគាត់ទេចឹង?

ខ៖  ចា៎!ថាម៉េច?

ក៖  អ៊ុំមានធ្លាប់ធ្វើអីគេខ្លះជាមួយពួកគាត់ដែរទេអ៊ុំ លក្ខណះថាដើរលេងជាមួយគ្នា?

ខ៖  អ្ហ៎!ដើរតែធ្វើត្បាញ់អីអោយគេនឹង
ខ្ញុំគ្មានដែរដើរលេងអីទេដើរស៊ីឈ្នួលគេរហូតនឹងធ្វើស្មៅ ដើរស៊ីឈ្នួលគេគ្រប់កន្លែងនឹង ឥឡូវនឹងទើបតែឡើងពីកាត់ស្មុំអោយគេ រួចប្ដីរបស់ខ្ញុំបេះស្លឹកឈូកចឹង ហាស

ក៖  អ្ហ៎!បេះស្លឹកឈូកយកទៅលក់ហោសអ៊ុំ?

ខ៖  ចា៎!បេះស្លឹកឈូកយកទៅលក់នឹងអោយគេ

ក៖  គេទិញស្លឹកឈូកយកទៅធ្វើអីគេដែរអ៊ុំ?

ខ៖  ចា៎!!!!?

ក៖  គេទិញស្លឹកឈូកយកទៅធ្វើអីគេដែរអ៊ុំ?

ខ៖
ទិញគេតើនឹងយើងទៅបឹងគេទិញបានមួយម៉ឺនទៅពីរម៉ឺនអីចឹងមកលក់ចំណេញបានខ្លះៗ ទៅចឹង ខ្លះអត់បានរួចតែដើមនឹង

ក៖ ប៉ុន្តែគេទិញស្លឹកឈូកយកទៅធ្វើអីគេដែរអ៊ុំ?

ខ៖ អូ៎!គេទិញនឹងដើម្បីយកទៅខ្ចប់បាយនឹងហាស

ក៖ អូ៎!ដើម្បីខ្ចប់បាយហោសអ៊ុំ?

ខ៖ ចា៎!យកទៅខ្ចប់បាយហាសយើងនឹងហាស

ក៖ បាទចុះអ៊ុំចូលចិត្តលេងអីគេជាមួយប្អូនរបស់អ៊ុំដែរ?

ខ៖ ចា៖!!!?

ក៖ អ៊ុំចូលចិត្តលេងអីគេជាមួយប្អូនរបស់អ៊ុំដែរនឹង?

ខ៖ ប្អូនរបស់ខ្ញុំហោស?

ក៖ បាទចូលចិត្តលេងអីគេដែរអ៊ុំ?

ខ៖ ប្អូនរបស់ខ្ញុំនឹងអត់មានធ្វើអីទេគ្រាន់តែធ្វើទឹកកកស៊ីឈ្នួលគេនឹង
នឹងអាទឹកកករទេះហាស ទឹកកក អនាម័យហាស

ក៖ ចំប្អូនរបស់អ៊ុំធ្វើអីគេដែរអ៊ុំ?

ខ៖ នៅណោះនៅរហូតដល់ស្អីទៅប្រសិទ្ធិហោសនៅប្រសិទ្ធិហោសនៅជិតប្រសិទ្ធិហោស

ក៖ អូ៎!នៅប្រសិទ្ធិហោសអ៊ុំ?

ខ៖ គេហៅថាគីឡូលេខ9យ៉ាងម៉េចហោស?

ក៖ បាទអ៊ុំ?

ខ៖ ចា៎!គាត់នៅណុង

ក៖ ទាំងពីរនាក់ប្អូនរបស់អ៊ុំទាំងពីរនាក់នឹងនៅណុងទាំងពីរនឹងហោសអ៊ុំ?

ខ៖ អត់ទេនៅតែមួយទេតែមួយប្រុសទេ ឯមីស្រីនេះដើរបេះបន្លែនឹង

កៈ  គាត់នៅនឹងហោសអ៊ុំ?

ខៈ  នៅមខហោសនៅកន្លែងផ្ទះស័ង្កសីដែរគេទើបតែធ្វើនឹងហាស

កៈ  បាទអ៊ុំ ចុះឪពុករបស់អ៊ុំមានឈ្មោះអីគេដែរអ៊ុំ?

ខៈ ឪពុកខ្ញុំនឹងមានឈ្មោះជឹង ឈ្មោះសៅ ជឹង

កៈ  ចុះគាត់ឆ្នាំនឹងគាត់អាយុប៉ុន្មានអ៊ុំមានដឹងទេ?

ខៈ  គាត់ស្លាប់ហើយនឹងគាត់ស្លាប់តាំងពីជំនាន់អាពតគេយកទៅវៃចោលហោស

កៈ  បាទអ៊ុំចុះម្តាយរបស់អ៊ុំនឹងគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ  ណាគេម្តាយរបស់ខ្ញុំនឹងឈ្មោះសំ រី

ក  ចុះម្តាយរបស់អ៊ុំគាត់អាយុប៉ុន្មានដែរអ៊ុំ?

ខៈ ណោះម្តាយរបស់ខ្ញុំនឹងនៅអង្គុយលេងនៅមុខហោស

កៈ  អូ្ហ!គាត់អាយុប៉ុន្មានដែរអ៊ុំ?

ខៈ  គាត់អាយុប៉ុន្មានទេម៉ែខ្ញុំប្រហែលជាអាយុចិតជាងហើយនឹង

កៈ  ចុះម្តាយរបស់អ៊ុំនឹងគាត់កើតនៅណាដែរអ៊ុំមានដឹងទេ?

ខៈ
ចា៎!ម៉ែខ្ញុំនឹងកើតនៅស្រុកចុងតំម៉ៅនឹងស្រុកគាត់នៅចុងតាម៉ៅនឹងតែម្តងខ្ញុំទើបតែផ្លាស់មក
នៅនេះ

កៈ  បាទអ៊ុំចុះឪពុករបស់អ៊ុំនឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខៈ  ម៉ែរបស់ខ្ញុំនឹងហោសដើរបេះត្រកួននឹងបេះប្រលិតនឹង

កៈ  អូ្ហ!ម្តាយរបស់អ៊ុំហោសអ៊ុំ?

ខៈ ម្តាយរបស់ខ្ញុំនឹង

កៈ  អូ្ហ!ចឹងគាត់ដើរបេះត្រកួនទៅ?

ខ៖  ហើយឪពុករបស់ខ្ញុំពីសងញកមនឹងដើរតភ្លើងតអីអោយគេនឹង នៅស្ទឺគេទេគេហៅមេភ្លើងហោស

ក៖  បាទអ៊ុំបាទ?

ខ៖  ទៅធ្វើការអោយគេស៊ីឈ្នួលអោយគេខាងមេភ្លើងហោស នឹងឪពុកិរបស់ខ្ញុំនឹង

ក៖  ចុះម្ដាយរបស់អ៊ុំគាត់ស្លូតរឺមួយក៏កាចដែរអ៊ុំ?

ខ៖  ស្លូតដែរតើ?

ក៖  ចុះឪពុករបស់អ៊ុំវិញគាត់ស្លូតរឺមួយក៏កាចដែរអ៊ុំ?

ខ៖  គាត់ស្លូតដូចគ្នានិយាយទៅស្លូតទាំងអស់នឹង

ក៖  ចុះអ៊ុំមានចងចាំអនុស្សាវរីយ៍អីកាលពីអ៊ុំនៅជាមួយម្ដាយឪពុករបស់អ៊ុំអត់ធ្លាប់ដើរលេងជាមួយគ្នា?

ខ៖  អ៊ូ!ខ្ញុំអត់ចាំផងខ្ញុំភ្លេចបាត់ហើយនឹងខ្ញុំបានភ្លេចអស់ហើយនឹង

ក៖  ចុះធ្លាប់ទៅស្រែអីជាមួយគ្នាដែរទេអ៊ុំ?

ខ៖ ចា៎!កាលពីក្មេងនឹងមិនចេះនៅណុងទេចេះតែនៅរៀនអីទេណាស់

ក៖  បាទអ៊ុំបាទ?

ខ៖  ទៅរៀនកាលពីតូចនឹង រួចខ្ញុំទៅជួយដាំបន្លែអីជាមួយម្ដាយរបស់ខ្ញុំនឹងណាស់ គាត់ដាំត្រឡាចដាំអីនៅក្រោយវត្តនឹងហាស

ក៖  បាទអ៊ុំបាទចឹង?

ខ៖  ខ្ញុំចេះតែជួយធ្វើចំការគាត់នឹងហាស

ក៖  ចុះឪពុករបស់អ៊ុំនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅអ៊ុំទេ?

ខ៖  អត់ទេ

ក៖  ចឹងអត់ដែរទេណាអ៊ុំ?

ខ៖

ចា៎!ចុះបើខ្ញុំមានបានអីចាំបើខ្ញុំនៅតូចមួយដល់ពេលដែរគេបែកអាពតមកគេយកប៉ារបស់ខ្ញុំនឹងទៅ វៃចោលបាត់ខ្ញុំមានបានចាំណា

ក៖

ចុះម្ដាយរបស់អ៊ុំនឹងគាត់មានដែរប្រាប់ពីប្រវត្តិរបស់គាត់កាលពីគាត់នៅក្មេងទៅអ៊ុំដែរទេអ៊ុំ?

ខ៖

ម៉ែរបស់ខ្ញុំនឹងក៏គាត់វង្វេងដែរនឹងដល់ពេលដែរប្អូនរបស់ខ្ញុំបានស្លាប់ពីរជំនានអាពតនឹងបានស្លាប់

អស់ពីរនាក់នឹងហើយឪពុកខ្ញុំគេយកទៅវៃចោលទៀតម៉ែរបស់ខ្ញុំនឹងចង់បណ្ណាចារ្យហើយនឹង ឡើងចង់ ឆ្កួតហាសកាលណុង

ក៖ បាទអ៊ុំបាទចឹង?

ខ៖ ឥឡូវនឹងគាត់ភ្លេចភ្លាំងគាតអស់ហើយនឹង

ក៖ ឥឡូវនឹងគាត់ភ្លេចអស់ហើយណាអ៊ុំ?

ខ៖ ចា៎!គាត់ភ្លេចអស់ហើយនឹង

ក៖ ចុះយាយតាខាងឪពុកនឹងអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ ចា៎!!!!?

ក៖ យាយតាខាងឪពុកហាស?

ខ៖ ខាងឪពុកនឹងស្លាប់អស់ដែរ

ក៖ ប៉ុន្តែអ៊ុំមានស្គាល់ឈ្មោះពួកគាត់ដែរទេអ៊ុំ?

ខ៖ ខ្ញុំស្គាល់ដែរតើ

ក៖ ពួកគាត់មានឈ្មោះអីគេខ្លះដែរអ៊ុំ?

ខ៖ គាត់មានឈ្មោះសៅ សួន

ក៖ នឹងតា?

ខ៖ ឈ្មោះយាយ ផូ

ក៖ ចុះយាយតាខាងម្តាយវិញអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ ខាងម្តាយវិញគាត់ឈ្មោះតាលុញ

ក៖ ចុះយាយវិញអ៊ុំ?

ខ៖ ឈ្មោះយាយរឿន

ក៖ ចុះអ៊ុំនៅនឹងយូរនៅអ៊ុំ?

ខ៖ ចាំ!ខ្ញុំនៅនឹងយូរហើយនឹងខ្ញុំនៅតាំងបីបែកមកខ្ញុំនៅតែនឹងរហូតនឹង

ក៖ ចឹងជាង40ឆ្នាំហើយណាអ៊ុំ?

ខ៖ ចាំ!តាំងពីបែកមកយើងចូលមកហាសយើងនៅនឹងរហូតនឹង

ក៖ ចុះអ៊ុំមានបងប្អូនរឺមួយក៏កូនចៅណាដែររស់នៅក្រៅប្រទេសទេអ៊ុំ?

ខ៖ អត់
អត់មានសោះខ្ញុំអត់មានកូនចៅណាដែរនៅក្រៅពីខេត្តកណ្តាលនឹងទេនៅតែក្នុងនឹងទាំងអស់នឹង

ទើបតែទៅកាស៊ីណូទើបតែទៅស៊ីឈ្នួលអោយគេតើ

ក៖ បាទអ៊ុំចុះប្តីរបស់អ៊ុំនឹងគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ គាត់មានឈ្មោះអឿន ឈ្មោះសេង សំអឿន

ក៖ បាទអ៊ុំ
ចុះអ៊ុំមានចងចាំថ្ងៃដែរអ៊ុំរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅថ្ងៃខែឆ្នាំណាដែរអត់អ៊ុំ?

ខ៖ តាំងពីថ្ងៃខែជួបគ្នាមកមែន?

ក៖ បាទតាំងពីការហាស?

ខ៖ អ៊ូ!មើលឆ្នាំ1986

ក៖ ចឹងឆ្នាំ1986ណាអ៊ុំ?

ខ៖  ចា៎!តាំងពីឆ្នាំ1986នឹង

ក៖  ចឹងនៅពេលដែរអ៊ុំចូល?

ខ៖  ខ្ញុំការមកឆ្នាំ1986

ក៖
ចុះនៅពេលដែរអ៊ុំបានជួបគ្នាជាមួយអ៊ុំប្រុសនឹងដូចជាអ៊ុំអ្នករៀបចំខ្លួនឯងរឺមួយក៏ម្ដាយឪពុកជាអ្នក រៀបចំការអោយដែរ?

ខ៖  នៅក្នុងឆ្នាំតែម្ដងនឹង

ក៖  ប៉ុន្តែឪពុកម្ដាយរបស់អ៊ុំជាង្នកការអោយទេណា?

ខ៖  នៅក្នុងឆ្នាំនឹងខែប៉ុន្មានទេខ្ញុំចេះតែភ្លេចខែប៉ុន្តែឆ្នាំនឹងខ្ញុំដឹងថាឆ្នាំ1986នឹងតែម្ដងនឹង

ក៖  ប៉ុន្តែឪពុកម្ដាយរបស់អ៊ុំគាត់ជាអ្នករៀបការអោយគាត់ជាអ្នករៀបចំអោយទេណាអ៊ុំ?

ខ៖  ចា៎!គាត់ជាអ្នករៀបចំអោយនឹងកាលឆ្នាំ1986នឹង វាភ្លេចថ្ងៃទៅ

ក៖  ចុះអ៊ុំប្រុសកាលពីអ៊ុំប្រុសគាត់មកស្ដីដណ្ដឹងអ៊ុំនឹងដូចជាមានជាជំនូនអត់អ៊ុំ?

ខ៖  ចា៎!ខ្ញុំភ្លេចអស់ដែរនឹងហាសខ្ញុំភ្លេច

ក៖  អូ៎!ភ្លេចអស់ហើយណាអ៊ុំ?

ខ៖  ចា៎!ខ្ញុំភ្លេចថ្ងៃនឹងភ្លេចខែនឹង

ក៖  ប៉ុន្តែចង់និយាយថាពេលដែរអ៊ុំប្រុសចូលមកស្ដីដណ្ដឹងអ៊ុំនឹងជាជំនូនរឺថ្លៃទឹកដោះអត់អ៊ុំ?

ខ៖  មានកាលពីជំនាន់ណុងលុយថាបាន300នឹង

ក៖  អូ៎!បាន300ហោសអ៊ុំ?

ខ៖  បាន300នឹងថោកនឹងហាសកាលពីជំនាន់ណុងយើងអង្ករមួយរៀល នឹងពីររៀលនឹង

ក៖ បាទអ៊ុំបាទនឹង?

ខ៖  អង្ករមួយគីឡូបីរៀលនឹងខ្ញុំដើរស៊ីឈ្នួលគេមួយថ្ងៃបាន4ពាន់

កៈ បាទអ៊ុំចុះ?

ខៈ កាលណុង4ពាន់ច្រើនណាស់កាលណុង

កៈ ចុះជុំមានចេះខ្មែរទេអ៊ុំ អ៊ុំរៀនបានថ្នាក់ទីប៉ុន្មានដែរអ៊ុំ?

ខៈ ខ្ញុំហេសរៀនបានថ្នាក់ទី5នឹង

កៈ អូ!ចុះអ៊ុំរៀននឹងនៅសាលាណាដែរអ៊ុំ?

ខៈ ចា៎!!!?

កៈ សាលានៅណាដែរអ៊ុំ?

ខៈ សាលានៅក្រោមហោសនៅស្វាយរលំហោស

កៈ ឈ្មោះអីគេដែរអ៊ុំសាលារបស់អ៊ុំហាស?

ខៈ គេហៅសាលាសាមគ្គី

កៈ អូ!បឋមសិក្សាសាមគ្គី?

ខៈ ចា៎!សាលាសាមគ្គី

កៈ ចុះអ៊ុំធ្លាប់មានមិត្តភក្តិដែរធ្លាប់ធំធាត់មកជាមួយគ្នាទេអ៊ុំ?

ខៈ អត់ខ្ញុំអត់ដឹងនឹងហាស

កៈ អូ!ចុះអ៊ុំមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេអ៊ុំ?

ខៈ អត់ទេឥឡូវខ្ញុំភ្លេចភ្លាំងអីអត់មើលមិនឃើញអីទៀតនឹងដូចថាភ្នែកមលអត់ឃើញ

កៈ អូ!អ៊ុំអន់ភ្នែកហើយណអ៊ុំ?

ខៈ

ចា៎!អន់ភ្នែកហើយនឹងត្រចៀកខ្ញុំស្តាប់អត់បានទេកាលណុងប្តីរបស់ខ្ញុំនឹងធ្វើបាបខ្ញុំពេកហាសធ្វើបាប ខ្ញុំតាំងពីខ្ញុំនៅក្មេងខ្ទីហោស

កៈ អូ!បាទអ៊ុំចឹងហោស?

ខ៖  ធ្លាក់ច្រាន់មកបីថ្ងៃចាចឹងក៏ហឹងត្រចៀកមួយចំហៀងនឹងទៅ

ក៖  ចុះសុខភាពរបស់អ៊ុំនឹងឥឡូវនឹងយ៉ាងម៉េចដែរ?

ខ៖  ចាំ!!!?

ក៖  សុខភាពរបស់អ៊ុំហាស?

ខ៖  សុខភាពហោស

ក៖  បាទអ៊ុំបាទសុខភាពហាស៑

ខ៖  សុខភាពរបស់ខ្ញុំគ្មានអីខ្ញុំចេះតែរស់ក្រពះដែរនឹងអូន
ហូបហើយរមួលចេះតែចុកក្រពះហាស

ក៖  បាទអ៊ុំចុះអ៊ុំគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះ?

ខ៖ ចាំ!ខ្ញុំទើបតែវះហើយបានប៉ុន្មានខែនឹងដែរតើ

ក៖  បាទអ៊ុំបាទ?

ខ៖  ខ្ញុំទើបតែវះពោះវៀនដុះខ្នែងនឹង

ក៖  ចុះអ៊ុំគិតថាតាំងពីក្មេងរហូតមកដល់ឥឡូវនឹងអ៊ុំគិតថាអ៊ុំធ្លាប់ធ្វើការងារអីគេខ្លះដែរអ៊ុំ?

ខ៖  ធ្វើការងារស៊ីឈ្នួលទៅកាត់ស្មៅអោយគេ

ក៖  ចឹងហោសអ៊ុំ?

ខ៖ ចាំ!អូនរុយជើងហើយអូនអង្គុយលើគ្រែទៅ

ក៖  អត់អីទេអ៊ុំខ្ញុំអង្គុយនៅនឹងក៏បានដែរ?

ខ៖  ហោឡើងមកអង្គុយលើគ្រែមកនឹង

ក៖  អត់អីទេអ៊ុំខ្ញុំអង្គុយនៅនឹងក៏បានដែរអ៊ុំដោយសារតែអ៊ុំជាម្ចាស់ផ្ទះចឹងមិនជាបញ្ហាអីទេអ៊ុំ

ខ៖ ចឹងហោសមិនអីទេចឹង

ក៖  ចុះអ៊ុំធ្លាប់ទៅធ្វើស្រែចំការទេអ៊ុំ?

ខ៖ អត់មានអីទេនឹងអត់មានចំការទេខ្ញុំដើរស៊ីឈ្នួលគេនឹង គ្មានដីស្រែទេមានតែប៉ុណ្ណឹង

ក៖ បាទអ៊ុំបាទ?

ខ៖ ចាំ!ខ្ញុំក្រខ្ញុំមានតែប៉ុណ្ណឹងឯងនៅមាត់ព្រែកនឹង

ក៖ ចុះអ៊ុំគិតថាជីវិតរបស់អ៊ុំនឹងមានការផ្លាស់ប្តូរអីគេដែរអ៊ុំតាំងពីក្មេងរហូតមកដល់ឥឡូវនឹងហាស?

ខ៖ អត់ទេអត់មានផ្លាស់ប្តូរអីទេអ៊ុំវេទនាណាស់មើលតែផ្ទះខ្ញុំនឹងដឹងហើយនឹង

ក៖ បាទអ៊ុំចុះអ៊ុំចូលចិត្តពិសារម្ហូបអីគេដែរអ៊ុំ?

ខ៖ ចាំ!ថាម៉េច?

ក៖ អ៊ុំចូលចិត្តពិសារម្ហូបអីគេដែរអ៊ុំ?

ខ៖ អត់ផងនឹង

ក៖ និយាយពីម្ហូបហាស?

ខ៖ អូ៎!ម្ហូបហោសម្ហូបខ្ញុំចេះតែមានអី កូនចេះតែទិញត្រីយកមកធ្វើដូចជាទឹកគ្រឿងអីនឹងមានស្លអីតិចតួច ៗនឹងហាស

ក៖ ប៉ុន្តែអ៊ុំចូលចិត្តហាសអ៊ុំចូលចិត្តញ៉ាំអីគេដែរអ៊ុំ?

ខ៖ ចូលចិត្តតែសាច់ជ្រូកនឹង

ក៖ អ៊ុំចូលចិត្តសាច់ជ្រូកហោស?

ខ៖ ចូលចិត្តសាច់មាន់ ត្រីមិនសូវជាហូបទេនឹង

ក៖ អូ៎!បាទអ៊ុំចុះអ៊ុំចូលចិត្តលេងល្បែងប្រជាប្រិយ៍អីដែរអ៊ុំ?

ខ៖ ចាំ!ចូលចិត្តនឹង

ក៖ លក្ខណះលាក់កន្សែង បោះអង្គុញ ចោលឈូងអីចឹងហាស?

ខ៖ ចាំ!!!?

កៈ លាក់កន្សែងចោលឈូងអីនឹងអ៊ុំចូលចិត្តដែរតើហីអ៊ុំ?

ខៈ អត់ទេ

កៈ ចឹងអត់ទេណាអ៊ុំណា?

ខៈ អត់ចូលចិត្តទេនឹងហាស

កៈ ចុះអ៊ុំចេះច្រៀងទេអ៊ុំ?

ខៈ ចា៎!អត់ទេនឹង

កៈ ចុះអ៊ុំចូលចិត្តស្តាប់បទចំរៀងទេអ៊ុំ?

ខៈ ខ្ញុំចូលចិត្តដែរប៉ុន្តែខ្ញុំស្តាប់អត់សូវបានទេ ខ្ញុំអត់សូវលឺចឹង

កៈ បាទអ៊ុំបាទ?

ខៈ ចា៎!ខ្ញុំមិនចូលចិត្តទេ

កៈ
ចុះអ៊ុំគិតថាមាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់អ៊ុំនឹងចេះលេងឧបករណ៍ភ្លេងទេអ៊ុំ?

ខៈ ចា៎!!ថាម៉េច?

កៈ ចុះលេងឧបករណ៍ភ្លេងហាស?

ខៈ អត់

កៈ ចឹងអត់មាននរណាគេចេះទេណាអ៊ុំ?

ខៈ ចា៎!អត់មានទេ

កៈ ចុះផ្ទះរបស់អ៊ុំនឹងមានលក្ខណះបែបណាដែរអ៊ុំ?

ខៈ មានស្អីទេមានតែទូរទស្សន៍មួយនឹង

កៈ អូ៎!ប៉ុន្តែផ្ទះអ៊ុំនឹងផ្ទះឈើចឹងមែនទេអ៊ុំ?

ខៈ ចា៎!មានតែឈើចឹងពុកៗៗអស់ហើយនឹង

កៈ ចុះអ៊ុំគិតថាជំនាញអីគេដែរអ៊ុំគិតថាអ៊ុំចេះស្ទាត់ជំនាញដែរអ៊ុំ
ជំនាញអីដែរអ៊ុំចេះធ្វើវាហាស លក់ដូរអីមួយក៏អីចឹងហាសអ៊ុំ?

ខៈ ធ្វើអីក៏មិនកើត
ចុះយើងអត់លុយអត់កាក់ផងនឹងចេះតែដើរស៊ីឈ្នួលគេអោយមួយថ្ងៃនឹងរួចមួយថ្ងៃ
នឹងណាស់ចាមានបានផ្សំអី កូនទៅធ្វើការនៅណោះនឹងគ្រាន់តែគេបានចាយខ្លួនគេនឹង
ដូចថាគេទិញ ខោអាវស្លៀកពាក់អីខ្លួនឯងចឹងទៅណាស់

កៈ បាទអ៊ុំចុះឪពុកម្ដាយរបស់អ៊ុំនឹងធ្លាប់បង្រៀនពីជំនាញអីទៅអ៊ុំដែរទេ?

ខៈ អត់នៅតែផ្ទះនឹង

កៈ អូ!ចឹងនៅតែផ្ទះទេណអ៊ុំ?

ខៈ ចា៎!នៅតែផ្ទះនឹងចុះបើយើងចាស់ហើយនឹង

កៈ
ចុះអ៊ុំអាចប្រាប់ខ្ញុំពីការលំបាករបស់អ៊ុំកាលពីនៅក្មេងនឹងអ៊ុំមានការលំបាកអីគេខ្លះដែរអ៊ុំ?

ខៈ ចា៎!!!?

កៈ កាលពីក្មេងហាសអ៊ុំធ្លាប់មានការលំបាកអីគេដែរអ៊ុំ?

ខៈ ធ្វើអីមានធ្វើអីទេនឹងធ្វើតែស្មៅ ដើរកាប់អំពៅអោយគេ

កៈ កាលពីនៅក្មេងហោសអ៊ុំ?

ខៈ ចា៎!នឹងកាលពីនៅក្មេងនឹងណោះទៅកាប់អំពៅអោយគេរហូតដល់ព្រែកហូរ
ព្រែកត្រពាំងហោស

កៈ បាទអ៊ុំបាទ?

ខៈ
ទៅឆ្ងាយៗណាស់ដើរទៅឆ្ងយណាស់ក្រោកពីយប់ទៅនឹងយើងដាក់បាយទៅយើងព្រល
ប់ៗម៉ោង6 ល្ងាចបានមកដល់ផ្ទះវិញនឹងខ្ញុំវេទនាណាស់ខ្ញុំ

កៈ ចុះកាលពីអ៊ុំនៅជំនាន់លុនណុលអ៊ុំធ្លាប់ជួបការលំបាកអីគេដែរទៅអ៊ុំ?

ខ៖ អត់នៅតែរៀននឹង

ក៖ អូ៎!គេអត់មានចាប់អ៊ុំទៅណាទេណាអ៊ុំ?

ខ៖ ចា៎!នៅតែរៀននឹង

ក៖ ចុះកាលពីជំនាន់ពលពតវិញអ៊ុំ?

ខ៖ កាលពីជំនាន់ពលពតវិញគេអោយទៅចូលក្នុងអង្គភាព

ក៖ អង្គភាពនៅណាវិញទៅអ៊ុំ?

ខ៖ ចា៎!អង្គភាពកោះខ្យាច់រលាហោសនៅជិតកោះធំហោស

ក៖ អូ៎!គេជំលាសអ៊ុំទៅណុងហោស?

ខ៖
ចា៎!នៅក្រោមហោសនឹងហើយគេយកម៉ែរបស់ខ្ញុំនឹងទៅដាក់នៅនឹងពីព្រោះគេយកប៉ារបស់ខ្ញុំនឹងទៅ
វៃចោលបាត់ហើយនឹងហើយគេយកពួកមេម៉ាយៗយកទៅដាក់នៅណុងហើយគេយកក្មេងៗនឹងទៅដាក់នៅណុងនៅអង្គភាពនឹងហើយគេធ្វើបាប

ក៖ ពេលណុងអ៊ុំចូល?

ខ៖ ចា៎!!!វៃកដីវៃកអីអោយគេចឹងទៅ

ក៖ អូ៎!ប៉ុន្តែពេលណុងអ៊ុំធំហើយណាអ៊ុំ?

ខ៖ ចា៎!មិនធំទេខ្ញុំអាយុ13-14ឆ្នាំនឹង
ទៅវៃកដីគេអោយទៅកាប់ដីគាស់គល់ឈើពីព្រោះដើមឈើធំៗហោស

ក៖ បាទអ៊ុំបាទ ប៉ុន្តែអ៊ុំធ្វើច្រើនហោស?

ខ៖
ចា៎!គេគួកគេដាក់ទណ្ឌកម្មអោយយើងធ្វើគាស់រឺសគាស់អីចឹញមកអោយអស់ចឹងទៅណាស់

ក៖ បាទអ៊ុំបាទចឹង?

ខ៖  ជូនណាគាស់មុងខ្មោច គាស់មុងខ្មោចនឹងណាស់

ក៖  គេគាស់យកទៅណាដែរអ៊ុំ?

ខ៖  គេគាស់មុងខ្មោចនឹងគេយកខ្មោចអីចេញចឹងហាស

ក៖  ប៉ុន្តែគេគាស់ធ្វើអីអ៊ុំ?

ខ៖  គេគាស់ដើម្បីអោយដីវាលស្រែស្រួរគេហាស
អូនឯងកាលពីជំនាន់អាពតនឹងមិនទាន់ដឹងកន្លែងនឹង ចឹងហោស

ក៖  ខ្ញុំអត់ដឹងទេ?

ខ៖  អូយវេទនាណាស់

ក៖  ចឹងបានខ្ញុំសួរអ៊ុំនឹងហាស ចុះចឹងបងប្អូនរបស់អ៊ុំនឹងទៅណាដែរទៅអ៊ុំ?

ខ៖  បងប្អូនរបស់ខ្ញុំហោសទៅបេះបន្លែបាត់អស់ហើយនឹង

ក៖  អត់ទេចង់និយាយថាកាលពីជំនាន់ពលពតគេអោយទៅណាដែរ?

ខ៖
កាលពីជំនាន់ពលពតនឹងប្អូនរបស់ខ្ញុំពីរនាក់ណោះស្លាប់អស់ហើយនឹងវេទនាណាស់ចា

ក៖  ចុះបងៗរបស់អ៊ុំគេអោយទៅណាដែរ?

ខ៖  ប្អូនៗរបស់ខ្ញុំនឹងស្លាប់ដោយសារតែអត់បាយ
អត់បាយស៊ីបបរព្រលិតហើយស្លក៏ព្រលិតដែរនឹង ហើយវាមិនចេះហូប

ក៖  អូ៎!បាទអ៊ុំបាទ?

ខ៖ ដល់ពេលដែរវាមិនចេះហូបទៅឈឺៗៗរហូតទាល់តែស្លាប់ទៅនឹង

ក៖  ប៉ុន្តែបងរបស់អ៊ុំនឹងគេអោយទៅណាដែរ?

ខ៖  ចា៎!!!?

ក៖  បងៗៗរបស់អ៊ុំហាស?

ខ៖  ខ្ញុំនឹងហើយបងគេនឹង

ក៖ អូ៎!ចឹងហោសអ៊ំ?

ខ៖ ចា៎!នឹងហើយប្អូនរបស់ខ្ញុំនឹងស្លាប់អស់2នាក់ទៅនឹងហាស

ក៖ ចុះគេមានជំលាសអ៊ំទៅណាទៀតអ៊ំ?

ខ៖ ចា៎!ថាម៉េច?

ក៖ គេមានជំលាសអ៊ំទៅកន្លែងណាផ្សេងទៀតអអត់អ៊ំ?

ខ៖ អត់ដល់ពេលដែរបែកនឹងយើងមកនឹងតែម្តងនឹង

ក៖ ចុះម្តាយរបស់អ៊ំពេលណុងគេអោយធ្វើអីដែរអ៊ំ?

ខ៖
ម៉ែរបស់ខ្ញុំនឹងកាលពីជំនាន់អាពតនឹងគេអោយគេមើលក្មេងៗៗនឹងធ្វើជាមេដោះចុះគាត់កូនខ្ចីនោះ ចាកាលណុងមេដោះសុទ្ធតែក្មេងៗៗនឹងសុទ្ធតែតូចៗនឹង

ក៖ ប៉ុន្តែអ៊ំនៅតែម្តុំកោះធំនឹងទេ?

ខ៖ ចា៎!នៅមុខកោះធំនៅក្រោមហោសអត់មានដើរទៅដល់ណុងទេហោសចៅ

ក៖ ចឹងអ៊ំនៅតើ ជំនាន់ពលពតនឹងអ៊ំនៅតែនឹងទេ?

ខ៖ នៅក្រោមហោស

ក៖ អ៊ំទៅនៅដល់កោះធំហោសអ៊ំ?

ខ៖
ចា៎!នៅផ្សារចំនៀរនៅជិតកោះធំហោសចានៅណុងគេយកទៅដាក់នៅណុងគេយកទៅវៃចោល ហាស

ក៖ បាទអ៊ំ ចុះរហូតមកដល់ការរំដោះនឹងអ៊ំមានការលំបាកអីទេអ៊ំ?

ខ៖ រួចយើងមកដល់នឹងមកនឹងយលងនាំម៉ែកូននឹងមកនឹង
នៅតែពីរនាក់ម៉ែកូននឹងពីព្រោះឪពុកនឹងគេ យកទៅវៃចោលអស់ហើយនឹង
អត់រលីងនឹងពូរបស់ខ្ញុំនឹងក៏យកទៅវៃចោលដែរនឹង

កៈ ប៉ុន្តែចង់និយាយថាផុតការរំដោះហាស ផុតពលពតហាសមានការលំបាកអីគេដែរអ៊ុំ?

ខៈ
លំបាកយើងមិនមានអីហូបចឹងហាសគេចែកពោតគេចែកដំឡូងនឹងដំឡូងអោយម្នាក់មួយមឺមនឹង ហើយគេអោយទឹកសំលម្នាក់បន្តិចៗៗនឹងហុតជាមួយដំឡូងនឹងហាស

កៈ បាទអ៊ុំ?

ខៈ
ចា៎!គេយកប៉ារបស់ខ្ញុំនឹងទៅវៃចោលនឹងហាសគេលុតដំចឹងហាសពេលណុងខ្ញុំស្គមនឹងថាខ្ញុំទៅដែរ ហើយនឹង ចេះមកនឹងចេះបែកទាន់នឹង

កៈ បាទអ៊ុំចុះបែកអ៊ុំទៅណាវិញទៅអ៊ុំ?

ខៈ ចា៎!ខ្ញុំមកនឹងមក

កៈ ចុះពេលណុងអ៊ុំធ្វើអីគេដែរអ៊ុំ?

ខៈ មកនឹងមកកិបានគេចែកដីស្រែដីស្រូវនឹងមកនឹងម៉ែរបស់ខ្ញុំគាត់អត់យកកាលណុងចឹងបានក្រដល់សព្វថ្ងៃនឹងទៅ វាមានដីស្រែដីស្រូវ មានដីផលដីមុខដីថ្នល់អីចឹងទៅណាស់

កៈ បាទអ៊ុំគាត់មិនយកហោស?

ខៈ ដល់ពេលដែរម៉ែរបស់ខ្ញុំនឹងគាត់មិនចង់បាននឹង

កៈ ដល់ពេលចឹងអត់ទៅ?

ខៈ ចា៎!ដល់ហើយក្រដល់សព្វថ្ងៃនឹងទៅ

កៈ អ៊ូ!បាទអ៊ុំចុះអ៊ុំគិតថាជីវភាពរបស់អ៊ុំនឹងយ៉ាងម៉េចដែរអ៊ុំ?

ខៈ ចា៎!!!?

កៈ ជីវភាពរបស់អ៊ុំនឹងសព្វថ្ងៃនឹងយ៉ាងម៉េចដែរអ៊ុំ?

ខៈ ជីវភាពរបស់ខ្ញុំសព្វថ្ងៃនឹងវេទនាណាស់អង្ករមួយគីឡូ ព្រឹកមួយគីឡូល្ងាច

កៈ ប៉ុន្តែអ៊ុំធ្វើអីគេឥឡូវនឹង?

ខ៖ ចាំ!ថាម៉េច?

ក៖ អ៊ុលក់ដូរអីគេទៅឥឡូវនឹងអ៊ុំ?

ខ៖ អត់លក់ដូរអីទេទៅស៊ីឈ្នួលទៅបេះស្លឹកឈូកនឹងបេះស្លឹកស្ពំអោយគេនឹង
មួយថ្ងៃបានតែ25000
ព្រឹកចឹងបាន12500នឹងដល់រល់ល្ងាចបាន25000ចឹងហាសណាស់ទុកគ្រាន់បានទិញអង្ករ
ហូបពីរនាក់តា នឹងយាយនឹងកាច់ឈូកនឹង

ក៖ ចុះអ៊ុំទៅបេះស្លឹកឈូកនៅណាដែរអ៊ុំ?

ខ៖ ស្លឹកឈូកនឹងទៅឆ្ងាយៗណាស់មានកង់កញ្ចាស់មួយសំរាប់ដឹកឈូកនឹង

ក៖ អូ៎!អ៊ុំទៅកាច់ខ្លួនឯងហោសអ៊ុំ?

ខ៖ នៅឆ្ងាយហាសទៅដល់ណោះហោស

ក៖ អ៊ុំទៅកាច់ឈូកខ្លួនឯងហោសអ៊ុំ?

ខ៖
បើយើងមិនមានលុយទិញទេយើងមើលឃើញបឹងមាននៅកន្លែងណាដុះចឹងយើងចុះបេះតិ
ចៗៗនឹង មកនឹងប៉ុន្តែឈ្លើង
មានឈ្លើងរម៉ាស់ណាស់បើប្អូនឯងហ៊ានតែប៉ះមើលមិនមានដង្កូវរម៉ាស់ នឹងមានឈ្លើង
ទៅតោងនឹងនៅជំនៀរនឹងហាស

ក៖ ចុះអ៊ុំទៅបេះស្ពំនឹងអ៊ុំទៅបេះនៅណាដែរ?

ខ៖ ទៅកាត់នៅក្នុងបន្ទាយហោសកាត់អោយគេ

ក៖ មួយនឹងគេអោយអ៊ុំទៅកាត់ហោសអ៊ុំ?

ខ៖ ចាំ!គេអោយទៅកាត់ទៅនឹង

ក៖ អូ៎!បាទអ៊ុំ ចុះអ៊ុំឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរអ៊ុំ?

ខ៖ ខ្ញុំពិបាកណាស់នឹងហាសឆ្លងកាត់ដល់ទៅគក់ខោអាវអីអោយគេនឹង
នឹងបោកអនាម័យអោយគេចឹង ទៅណាស់

កៈ បាទអ៊ុំបាទអ៊ុំចឹងហោស?

ខៈ
មានលាងបង្គន់អីអោយគេចឹងទៅនឹងដើរស៊ីឈ្នួលអោយគេរែកទឹកបានមួយពាងៗអោយ
គេបានតែ 3000-4000អីនឹង

កៈ អ៎ូ!មានរែកទឹកដែរហោសអ៊ុំ?

ខៈ ចា៎!មានរែកទឹកអោយគេទៀតនឹងហាស

កៈ ចុះអ៊ុំទៅដល់ណាដែរទៅអ៊ុំ?

ខៈ ខ្ញុំទៅទន្លេហោស
កាលណុងហាសដល់ពេលដែរឥឡូវនឹងដល់ពេលដែរមានអណ្តូងនឹងចេះតែរែកៗ
ទៅនឹងដូចថាអណ្តូងដែរត្រូវការអីចឹងទៅរែកនៅអណ្តូងហើយស្នប់គេនៅមុខនេះនឹង

កៈ បាទអ៊ុំបាទ?

ខៈ យកមកៗៗនឹងបានមួយពាងនឹងបានប្រហែល3000-
3500អីនឹងគ្រាន់ទុកដោះស្រាយជីវភាពយើង នឹងហាស

កៈ ចុះអ៊ុំគិតថាពេលណាដែរអ៊ុំគិតថាជាពេលដែរសប្បាយជាងគេដែរអ៊ុំ?

ខៈ អត់មានសោះនឹងហាស

កៈ អត់មានការសប្បាយទេណាអ៊ុំ?

ខៈ អត់មានការសប្បាយនឹងគេទេនឹងវេទនារហូតនឹង

កៈ អ៎ូ!បាទអ៊ុំចឹង?

ខៈ ចុះយើងបានថ្ងៃនេះខ្លាចស្អែកអត់ទៀតនឹង

កៈ ម៉េចចឹងអ៊ុំ?

ខៈ ចុះខ្លាចអត់អីហូបនឹងយើងរកមិនបាននឹងហាស

កៈ ចឹងយលងត្រូវខំប្រឹងរកណោះអ៊ុំ?

ខ៖  ចា៎!ខំរកហើយនឹងខ្លួចអត់មានទិញអីហូបនឹងហាស

ក៖  ចុះអ៊ុំតាំងពីក្មេងនឹងអ៊ុំធ្លាប់មានក្ដីស្រម៉ៃថាពេលដៃរធំឡើងនឹងអ៊ុំចង់ធ្វើអីគេដៃរទេ?

ខ៖
កាលពីនៅក្មេងនឹងចង់រៀនដៃរអោយបានធ្វើការធ្វើងារនឹងគេទៅយើងក្រយើងរៀនបានត្រឹមថ្នាក់តែ ប៉ុណ្ណឹងហាស

ក៖  បាទអ៊ុំប៉ុន្ដែគោលបំណងអ៊ុំចង់ធ្វើអីគេដៃរអ៊ុំ?

ខ៖  ចា៎!!!?

ក៖  គោលបំណងរបស់អ៊ុំនឹងអ៊ុំចង់ធ្វើអីគេដៃរពេលដៃរធំឡើងហាស
កាលពីអ៊ុំនៅក្មេងហាស?

ខ៖
អត់អត់មានធ្វើអីផងនឹងដើរតែស៊ីឈ្នួលគេនឹងហាសមានបានលុយអីប៉ុន្មានចុះម៉ែយើងអត់មាន ទេនឹងហាសសុទ្ធក្រចឹងហាស

ក៖  ឪពុកម្ដាយរបស់អ៊ុំនឹងក្រដៃរហោសអ៊ុំ?

ខ៖
ចា៎!សុទ្ធតែក្រនឹងហាសម៉ែរបស់ខ្ញុំនឹងក្រណាស់យើងខ្ញុំក្រដៃរប៉ុន្ដែគាត់ដើតហូបស្រានឹងរហូតដល់ គាត់ស្លាប់នឹងគាត់ពិបាកចិត្តគាត់នឹង

ក៖  ម៉េចចឹងអ៊ុំ?

ខ៖  ចុះបើយើងក្រយើងមិនដឹងរកស៊ីអីគេដៃរមិនបានសល់អីនឹងគេហាស
ដល់ពេលហើយពិបាកចិត្ត ពិបាកគៅនិតគាត់ចេះតែហូបស្រាទៅរហូតដល់ស្លាប់នឹង

ក៖  បាទអ៊ុំចុះ?

ខ៖  អ៊ុំខ្ញុំស្លាប់ដោយសារតែស្រាទាំងអស់នឹងហាស

ក៖  ចុះម៉េចចឹងអ៊ុំ?

ខ៖ ពិបាកចិត្តដោយសារតែក្រនឹងចិញ្ចឹមកូន ចិញ្ចឹមចៅមិនរស់នឹង

កៈ អូ!ប៉ុន្តែអ៊ុំអត់មានអីទេណាអ៊ុំ?

ខៈ ចា៎!ខ្ញុំមិនអីទេខ្ញុំអត់ហូបអត់អីទេនឹង

កៈ អ៊ុំមិនចេះហូបស្រាទេណាអ៊ុំ?

ខៈ ចា៎!នឹងហើយមិនចេះទេនឹង ពីមុននឹងខ្ញុំហូបដែរប៉ុន្តែតាំងពីវះមកខ្ញុំឈឺ

កៈ គេឈប់អោយអ៊ុំហូបហើយចឹង?

ខៈ ចា៎!ពេទ្យគេហាមឈប់អោយហូបឈប់អោយអីចឹងទៅណាស់

កៈ អូ!បាទអ៊ុំចំអ៊ុំឈឺអីគេមែនអ៊ុំ?

ខៈ ខ្ញុំរវល់តែឈឺក្រពះនឹង

កៈ ចុះក្រពះនឹងកើតអីអ៊ុំ?

ខៈ ចា៎!ក្រពះនឹងវារមួលៗៗនឹង វាឈឺហាសចាហើយទើបតែពីវះចឹងទៀតនឹងហាស ពេកឈប់អោយ ហើយខ្លួចពោះវៀនយើងទៀតនឹងហាស

កៈ

បាទអ៊ុំចុះចង់អោយអ៊ុំផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗតើអ៊ុំចង់ផ្តែផ្តាំអីទៅពួកគាត់ដែរអ៊ុំ?

ខៈ អត់ៗៗចង់អីទេ

កៈ លក្ខណះផ្តែផ្តាំទៅពួកគាត់ហាស?

ខៈ អត់ទេ

កៈ ចុះអ៊ុំចង់អោយសង្គមយ៉ាងម៉េចដែរអ៊ុំ?

ខៈ អត់មានផ្តែផ្តាំអីទេនឹង

កៈ អូ!ចឹងហោសចឹងជាចុងក្រោយខ្ញុំអរគុណច្រើអ៊ុំ

ខៈ ចឹងបានហើយនឹង

កៈ អរគុណអ៊ុំ៕៕៕